# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤ សសរ

## សេចក្តីសំរេច

ស្តីពី

## ការបង្កើតគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្លែកូងកាចន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១ និងលេខ ៤១ សសរ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ
- យោងឃើញសេចក្តីសំរេចលេខ ១២ សសរ ស្តីពីការបង្កើតក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័ន ដើម្បីកែលំអបរិស្ថានវិនិយោគ និងសំរួលពាណិជ្ជកម្ម ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០៤
- អនុលោមតាមតំរូវការចាំបាច់នៃការងារ

## សំ រេ ច

**ប្រការ១ :** បញ្ចប់អាណត្តិនៃក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័ន ដើម្បីកែលំអបរិស្ថានវិនិយោគ និង សំរួលពាណិជ្ជកម្ម ដែលបានបង្កើតតាមសេចក្តីសំរេចលេខ ១២ សសរ ចុះថ្ងៃទី ២២ ខែមិនា ឆ្នាំ ២០០៤។

**ប្រការ២ :** បង្កើតគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **គាត ឈន់** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- ឯកឧត្តម **ជា ចាន់តូ** | អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៤- ឯកឧត្តម **ស៊ុយ សែម** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥- ឯកឧត្តម **ចំរុង សារុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦- ឯកឧត្តម **ស៊ុន ចាន់ថុល** | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧- ឯកឧត្តម **ឡាយ ប្រហស្ស** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ៨- ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

**ប្រការ៣ :** គណៈកម្មការដឹកនាំការងារ មានភារកិច្ចដូចតទៅ:

១- ធ្វើជាសេនាធិការឱ្យប្រមុខរាជរដ្ឋាភិបាល ក្នុងការកំណត់ ការដឹកនាំ ការអនុវត្តន៏ និងការតាមដាន សំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណលើចំណុចស្តីពីការអភិវឌ្ឍន៍ផ្នែកឯកជន

២- លើក និងដាក់ឱ្យអនុវត្តនូវវិធានការកែលំអបរិស្ថានវិនិយោគ

៣- លើក និងដាក់ឱ្យអនុវត្តនូវវិធានការសំរបសំរួលពាណិជ្ជកម្ម

៤- លើក និងដាក់ឱ្យអនុវត្តនូវវិធានការជំរុញសហគ្រាសធុនតូច និងមធ្យម

៥- លើក និងដាក់ឱ្យអនុវត្តនូវរាល់វិធានការដទៃទៀត ដើម្បីជំរុញការអភិវឌ្ឍន៍ផ្នែកឯកជន ។

**ប្រការ៤ :** ភារកិច្ចដូចមានចែងខាងលើនេះ នឹងត្រូវអនុវត្តក្នុងក្របខ័ណ្ឌក្រុមការងារតាមប្រធានបទ ។

**ប្រការ៥ :** គណៈកម្មការដឹកនាំការងារ ត្រូវរាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល អំពីបណ្តាវិធានការនានាដែលបានដាក់ចេញ ។ ក្នុងករណីដែលមានវិធានការលើសសមត្ថកិច្ចរបស់ខ្លួន គណៈកម្មការដឹកនាំការងារត្រូវរាយការណ៍ សុំការណែនាំ និងការសំរេចពីប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៦ :** ប្រធានគណៈកម្មការដឹកនាំការងារ អាចអញ្ជើញថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធមកចូលរួមការងារបាន ។ ពេលប្រធានអវត្តមាន គណៈកម្មការដឹកនាំការងារអាចប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន ឬ របស់តំណាងតាមការប្រគល់សិទ្ធិរបស់ប្រធាន ។

**ប្រការ៧ :** ក្នុងករណីចាំបាច់គណៈកម្មការដឹកនាំការងារនេះ អាចសហការជាមួយអ្នកផ្តល់ជំនួយ និង/ឬភាគីពាក់ព័ន្ធមកពីផ្នែកឯកជន ដើម្បីសំរេចបានប្រកបដោយប្រសិទ្ធភាពនូវភារកិច្ចខាងលើ ។

**ប្រការ៨ :** គណៈកម្មការដឹកនាំការងារ នេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនឹងសមាសភាពដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩
- ឯកសារ-កាលប្បវត្តិ